# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** : ០០១/១៦ **ក.ប**/សគពប

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៦

**ជម្រាបមក**
**លោក ស្រី ចំរើន**
**កញ្ញា ធី សុវណ្ណថា**

**កម្មវត្ថុ៖** សេចក្ដីព្រមានស្ដីពីការធ្វើសកម្មភាពសហជីពដោយមិនមានការអនុញ្ញាតតាមច្បាប់ស្ដីពីសហជីព។

**យោង៖** -ច្បាប់ស្ដីពីសហជីព

-ប្រកាសលេខ២៤០ក.ប/ប្រ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីការធ្វើប្រតិភូកម្មមុខងារក្នុងការអនុវត្តច្បាប់ស្ដីពីសហជីព

-លិខិតលេខ ១៦៩ សសកពក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ របស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា។

-ញត្តិសុំអន្តរាគមន៍ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៦ របស់តំណាងសហជីព កម្មករ-កម្មការិនី និងយុវជនចំនួន ១៥០នាក់

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ យើងសូមព្រមាន **លោក ស្រី ចំរើន** និង **កញ្ញា ធី សុវណ្ណថា** ថា យោងតាមច្បាប់ស្ដីពីសហជីព បុគ្គលដែលធ្វើសកម្មភាពសហជីព ឬសមាគមនិយោជកដោយមិនបានចុះបញ្ជី និងធ្វើសកម្មភាពក្រៅដែនអនុវត្តតាមទីតាំងភូមិសាស្ត្រ ឬតាមវិជ្ជាជីវៈ ឬតាមវិស័យដែលបានកំណត់ក្នុងលក្ខន្តិកៈរបស់ខ្លួន នឹងត្រូវរងវិធានការរដ្ឋបាល និងពិន័យអន្តរការណ៍។

យើងសូមព្រមានចំពោះ លោក ស្រី ចំរើន និងកញ្ញា ធី សុវណ្ណថា ថាត្រូវបញ្ឈប់រាល់សកម្មភាពសហជីពដោយមិនបានចុះបញ្ជីជាបន្ទាន់។ ក្នុងករណីនៅតែបន្តសកម្មភាពទៀត យើងនឹងអាចចាត់វិធានការដំណាក់កាលទី២ អនុលោមតាមច្បាប់ស្ដីពីសហជីព។

**តប. រដ្ឋមន្ត្រី**
**ប្រធាននាយកដ្ឋានវិវាទការងារ**

**គុយ ទេពជារាវុធ**